ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម

លេខ : ៦៦៨/១៧ ប.ស.ស

# សេចក្តីណែនាំ

## ស្តីពី

## សិទ្ធិទទួលបានប្រាក់សម្រាកមាតុភាព
## ចំពោះសមាជិក ប.ស.ស ដែលបានសម្រាលកូន
## នៅមូលដ្ឋានសុខាភិបាលមិនបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស

បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សូមជម្រាបលោក/លោកស្រីជាម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងសមាជិក ប.ស.ស ទាំងអស់ដែលបានចុះបញ្ជិកាផ្នែកថែទាំសុខភាពនៅ បេឡាជាតិរបបសន្តិសុខសង្គម ឲ្យបានជ្រាបថា៖ *សមាជិក ប.ស.ស ដែលបានសម្រាលកូននៅមូលដ្ឋានសុខាភិបាលមិនបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ទោះករណីសង្គ្រោះបន្ទាន់ក្តី មិនសង្គ្រោះបន្ទាន់ក្តី ហើយបានបំពេញកាតព្វកិច្ចបង់ភាគទានយ៉ាងតិច៩ខែជាប់គ្នា* អាចទាមទារប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការសម្រាកមាតុភាពពី ប.ស.សបាន លុះណាតែសាមីជនមកពិនិត្យតាមដានស្ថានភាពសុខភាពក្រោយសម្រាលនៅមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ។

បេឡាជាតិរបបសន្តិសុខសង្គម មានសង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងសមាជិក ប.ស.ស ទាំងអស់អនុវត្តតាមសេចក្តីណែនាំនេះឲ្យមានប្រសិទ្ធភាព។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១៧

**នាយក**

**អ៊ុក_សមវិទ្យា**

អាសយដ្ឋានអគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទ: ០២៣-៨៨ ២៤ ៣៤ , ០២៣ ៩៩ ៨៤ ១៧
០២៣-៩៩ ៨៤ ១៨ , ០២៣ ៩៩ ៨៤ ១៩

ទូរសារ : ០២៣ ៨៨ ២៦ ២៣ , ប្រអប់សំបុត្រ P.O.Box 70
Website : www.nssf.gov.kh